# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jul-2011, 14:54
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ការកត់សម្គាល់អំពីឯកសារដែលពាក់ព័ន្ធនឹងសវនាការជំណាក់កាលដំបូង

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Annebrecht VOSSENBERG

សាស្ត្រាចារ្យ Michael RAMSDEN

ផ្ញើជូន៖

**ក្រុមមេធាវីការពារក្តីទាំងអស់**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

STUDZINSKY Silke
Tristan TZARA

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

## I. សេចក្តីផ្តើម

១. ជាការឆ្លើយតបនឹងសំណើរបស់អង្គជំនុំជម្រះឲ្យ "ភាគីបញ្ជាក់អំពីឯកសារនានា ដែលខ្លួនយល់ថា ពាក់ព័ន្ធ នឹងអង្គហេតុដែលត្រូវធ្វើការជំនុំជម្រះដំបូងនេះ"[1] ("សំណើបញ្ជាក់ឯកសារ") មេធាវីការពារក្តី លោក នួន ជា ("មេធាវីការពារក្តី") សូមដាក់ការកត់សម្គាល់បឋម និងដាក់បញ្ចូលដោយយោងទៅសារណារបស់ខ្លួនអំពីការបញ្ជាក់ឯកសារក្នុងពេលសវនាការ ("សារណាបឋម")[2]។ ដូចហេតុផលរៀបរាប់ខាងក្រោមនេះ (និងអ្វីដែលបានលើកឡើងពីលើកមុន) មេធាវីការពារក្តីៈ (ក) រក្សាសិទ្ធិដើម្បីប្រើឯកសារផ្សេងៗ ដោយរាប់បញ្ចូលទាំងឯកសារដែលមានក្នុងសំណុំរឿង ក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD) ឬក៏ឯកសារផ្សេងទៀតនៅមុនពេលសវនាការលើអង្គសេចក្តី (ខ) នៅពេលនេះ មិនត្រូវបានតម្រូវ និង មិនអាចបញ្ជាក់ពីឯកសារជាក់លាក់ដែលខ្លួននឹងប្រើនៅពេលសវនាការ និង (គ) បង្ហាញក្នុងពេលសមស្របនូវឯកសារទាំងអស់ដែលខ្លួននឹងប្រើនៅចំពោះមុខអង្គជំនុំជម្រះ។

## II. ការកត់សម្គាល់

២. តាមពិតសវនាការបឋមមិនបានដោះស្រាយបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោម បើទោះជាគោលបំណងរបស់សវនាការនេះគឺជាឱកាសមួយដើម្បីបញ្ជាក់នូវបញ្ហាសំខាន់ផ្សេងៗសម្រាប់ពេលសវនាការខាងមុខក៏ដោយៈ

ក. នៅមិនច្បាស់នៅឡើយ "ថាតើ [មេធាវីការពារក្តី] នៅតែហាមឃាត់មិនឲ្យធ្វើការស៊ើបអង្កេតនៅមុនពេលសវនាការលើអង្គសេចក្តី ក្នុងនាម [ជនជាប់ចោទ]"[3]។ បើទោះជាមានការស្នើសុំជាដដែលៗពីមេធាវីការពារក្តីសុំឲ្យបញ្ជាក់លើចំនុចនេះ តែអង្គ

---

[1] ឯកសារលេខ E-1/4.1, "ប្រតិចារិតនៃសវនាការបឋម" សាធារណៈ , នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១, ERN 00712135-00712252 ("ប្រតិចារិតនៃសវនាការបឋម") ទំព័រទី២៥: ១១- ១៣។

[2] ឯកសារលេខ E-9/26 "ការជូនដំណឹងអំពីការចូលរួមជាមួយនឹង សារណាបឋមរបស់ លោក អៀង សារី ទាក់ទង នឹងឯកសារដែលត្រូវលើកយកមកសំអាងនៅសវនាការ និង សារណាបន្ថែមទាក់ទងនឹងឯក សារថ្មី" សាធារណៈ នៅថ្ងៃទី១៩ ខែ មេសា ឆ្នាំ ២០១១, ERN 00665546-00665543 (សារណាឯកសារលើកមុន)។

[3] ឯកសារ លេខ E-1/2.1, " ប្រតិចារិតនៃកិច្ចប្រជុំរៀបចំនៃកិច្ចសវនាការ" សម្ងាត់, នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១, ERN 00664215-00664345 ទំព័រ ១១៦:១០-១២ (បញ្ជាក់បន្ថែម)។

ជំនុំជម្រះមិនទាន់បានផ្តល់ការបង្គាប់ច្បាស់លាស់ណាមួយនៅឡើយទេ។ ខណៈដែលបញ្ហាទាក់ទងសាក្សីពិតជាត្រូវបានលើកឡើងក្នុងសវនាការបឋមដោយមេធាវីការពារក្តី ដែលរាប់បញ្ចូលអំពីវិសាលភាពនៃការអនុញ្ញាតឲ្យរកឯកសារថ្មី និងភស្តុតាងបានមកពីសាក្សី ក្រៅអំពីតែលទ្ធភាពធ្វើការទាក់ទងពួកគាត់ តែបញ្ហាដែលលើកឡើងដោយមេធាវីការពារក្តីនេះនៅតែមិនត្រូវបានដោះស្រាយនៅឡើយ[4]។

ខ. បញ្ជីបណ្តោះអាសន្នឈ្មោះសាក្សី ដែលនឹងត្រូវបានស្តាប់ចម្លើយក្នុងពេល ដែលគេហៅថា ដំណាក់កាលដំបូងនោះ (“បញ្ជីបណ្តោះអាសន្ន”) គឺទើបតែត្រូវបានប្រកាសក្នុងពេលថ្មីៗនេះ ដោយអង្គជំនុំជម្រះ[5]។ មេធាវីការពារក្តីបានជំទាស់នឹង “វិធានការធ្វើម្តងមួយៗ (និងមិនទាន់ចប់)នេះ” ដើម្បីចាត់ការនីតិវិធីជាបន្តបន្ទាប់ និងបានស្នើដាក់ឈ្មោះបន្ថែមទៀតទៅនឹងបញ្ជីបណ្តោះអាសន្ន ដើម្បីពិភាក្សានៅក្នុងសវនាការបឋមនាពេលខាងមុខជាសាធារណៈ[6]។ ឈ្មោះរបស់បុគ្គលនៅក្នុងបញ្ជីបណ្តោះ

---

[4] មើលប្រតិចារិតនៃសវនាការបឋម ទំព័រ២៤:៧-២៥:៧ ( អង្គជំនុំជម្រះបានទទួលសំណើរមួយចំ នួនពីភាគី ដែលបានស្នើសុំឲ្យមានការបញ្ជាក់អំពីការជួបទាក់ទងគ្នារវាងភាគី និង សាក្សីដើម បណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញនៅមុនពេលពួកគាត់ស្តាប់សក្ខីកម្មនៅសវនាការ។ ដោយ លក្ខណៈពិសេសនៃច្បាប់ស៊ីវិលឡដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺ ថាសាក្សីអ្នកជំនាញ ភាគច្រើនដែលពាក់ព័ន្ធនឹងសវនាការនេះ គឺត្រូវបានសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយរួចហើយ។ ដូច្នះ សាក្សីទាំងអស់នេះគឺជាសាក្សីដែលធ្លាប់ជាកម្មវត្ថុនៃកិច្ចដំ ណើរការនីតិវិធីរបស់តុលាការ ហើយប្រសិនបើពួកគាត់ត្រូវបានបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះ សាក្សីទាំងនោះនឹងត្រូវចាត់ទុកថាជាសាក្សីរបស់តុលាការ។ នៅក្នុងករណីមួយចំនួន និង ក្នុងករណីដែលអង្គជំនុំជម្រះមានភាពមន្ទិលពាក់ព័ន្ធនឹងភាពស៊ីសង្វាក់នៅចម្លើយទាំងនោះ ឬ ថាតើ សាក្សី ឬអ្នកជំនាញអាចរំឭកចំនុចសំខាន់ៗនៃចម្លើយរបស់ខ្លួនកន្លងមក អង្គជំនុំជម្រះអាចចាត់វិ ធានការនានាដើម្បីបញ្ជាក់ចំនុចមន្ទិលនេះឲ្យបានច្បាស់។ គ្រប់ករណីទាំងអស់ភាគីនឹងបានទទួល ការជូនដំណឹងអំពីគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះលើបញ្ហានេះ។ ប្រសិនបើអង្គជំនុំជម្រះទទួល យកសំណើរសុំស្តាប់សក្ខីកម្មរបស់សាក្សីថ្មី ឬអ្នកជំនាញថ្មីអង្គជំនុំជម្រះនឹងពិនិត្យមើលថា តើសក្ខីកម្មរបស់សាក្សី ឬអ្នកជំនាញថ្មីទាំងនោះធ្វើទៅអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងដែរឬ យ៉ាងណា? ក្នុងករណីមួយចំនួនអង្គជំនុំជម្រះក៏អាចធ្វើទំនាក់ទំនងជាមួយនឹងសាក្សី ឬអ្នកជំនាញ ដោយផ្ទាល់ ដើម្បីធានាថា តុលាការនឹងមិនបាត់បង់នូវពេលវេលាដ៏មានតម្លៃរបស់ខ្លួនក្នុងការកោះ ហៅសាក្សី ឬអ្នកជំនាញដែលសក្ខីមក្ខរបស់ពួកគាត់អាចនឹងស្របតាមខ្លឹមសារនៃវិធាន៨៧ អនុវិ ធាន៤ នៃវិធានផ្ទៃក្នុង។)

[5] សូមមើល ប្រតិចារិត សវនាការបឋម ទំព័រ ៧-៩។

[6] ឯកសារ E-93/9 “សំណើរសុំបន្ថែមសាក្សី និង បន្តសវនាការបឋម” សម្ងាត់ នៅថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១១, ERN 00711970-00711975។

អាសន្ន គឺស្ថិតនៅជាសម្ងាត់នៅឡើយ ដោយពិចារណាអំពីវិធានការការពារ[7] ដែលមិនទាន់ត្រូវបានបញ្ជាក់នៅឡើយ។ មេធាវីការពារក្តីក៏បានជំទាស់នឹងវិធានការនេះផងដែរ។ ដូចគ្នានេះដែរចំនួនសាក្សីទាំងអស់ដែលត្រូវស្តាប់ចម្លើយ និងចំនួន "ដំណាក់កាល"ទាំងអស់របស់សវនាការ មិនទាន់ត្រូវបានឲ្យដឹងនៅឡើយទេ។ វាទំនងដូចជាពិតទាំងស្រុងហើយថា អង្គជំនុំជម្រះនឹងមិនមានបំណងស្តាប់ចម្លើយសាក្សី[8] អំពីបញ្ហាដែលលើកឡើងដោយមេធាវីការពារក្តី[9]។

គ. ចំនួនដ៏ច្រើន និងភាពស្មុគស្មាញ ពិបាកយល់នៃសំណុំរឿង (និង SMD) ធ្វើឲ្យមានការលំបាក និងចំណាយពេលច្រើនក្នុងការកំណត់ឯកសារពាក់ព័ន្ធ និងបង្ហាញទៅជនជាប់ចោទឲ្យដឹង និងមានការឆ្លើយតបពីគាត់វិញ[10]។ ជាងនេះទៅទៀតនោះ ឯកសារទាក់ទងប្រកបដោយសក្តានុពលដែលកំពុងពិនិត្យយ៉ាងលម្អិតដោយមេធាវីការពារក្តីនៅក្នុងសំណុំរឿង រហូតមកដល់ពេលនេះ (ជាភាសាខ្មែរ និងអង់គ្លេស) នៅ

---

[7] សូមមើលឯកសារ ប្រតិចារិតសនាការបឋម ទំព័រ ១៧: ១២-១៥ ("បញ្ជីដែលត្រូវបានប្រគល់ទៅឲ្យភាគីជាលក្ខណៈសម្ងាត់ ហើយក៏បានបង្ហាញពីរហស្សនាមសម្រាប់ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះផងដែរ។ ក្នុងករណីដែលឈ្មោះរបស់សាក្សីអ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយត្រូវបានលើកឡើងក្នុងសវនាការនេះ ភាគីត្រូវប្រើរហស្សនាមរហូតដល់សេចក្តីសម្រេចចុងក្រោយ")។ ដូចគ្នា ទំព័រ ៤០: ១១-១៨ ( បញ្ហាដូចជាខាងអង្គជំនុំជម្រះបានបង្ហាញ សមល្មមនឹងអាចស្តាប់ចម្លើយបានហើយនូវហេតុផលទាំងឡាយនៃការដែលមិនទាន់ដល់ដំណាក់កាលត្រូវបង្ហាញខ្លួន.. អត្តសញ្ញាណជាសាធារណៈនូវសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី ដោយយើងគោរពនូវគោលការណ៍នៃវិធានការការពារសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់ពេលនេះអង្គជំនុំជម្រះមិនទាន់បានទទួលនូវរបាយការណ៍ពីអង្គភាពគាំពារសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលគេនឹងស្នើសុំវិធានការការពារ។ ហើយតើហានិភ័យនៃ បញ្ហានោះកម្រិតណា ដែលអង្គជំនុំជម្រះនឹងពិចារណាបន្តបន្ទាប់)។ សូមមើល ប្រតិចារិត សវនាការបឋម ទំព័រ ៣៩:១៨-២៤។ សំគាល់ ការពិតដែលថា បុគ្គលជាក់លាក់មួយត្រូវបានស្នើដោយភាគីមួយថា ជាសាក្សីសក្តានុពលមិនបានលើកឡើងពីវិធានការការពារបន្ទាន់ណាមួយទេ។

[8] សូមមើល ប្រតិចារិត សវនាការបឋម ទំព័រ ២៣:១៣-១៧ ("ដោយការពិចារណាទៅលើកាតព្វកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការធានាឲ្យមានការជំនុំជម្រះប្រកបដោយភាពឆាប់រហ័ស និងយុត្តិធម៌នោះ អង្គជំនុំជម្រះនឹងមិនកោះហៅសាក្សីដែលសក្ខីកម្មរបស់ពួកគាត់ទំនងជាមានភាពច្រំដែលជាមួយនឹងភស្តុតាងផ្សេងៗទៀតដែលមាននៅចំពោះមុខអង្គជំនុំជម្រះ")។

[9] សូមមើល ឯកសារ លេខ **E-9/10.1** "ឧបសម្ព័ន្ធ ឃ: សេចក្តីសង្ខេបរបស់សាក្សីជាមួយនឹងចំណុចនៃការចោទប្រកាន់" ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១, ERN 00646679–00646736។

[10] សូមមើលសារណាបឋម កថាខណ្ឌ ៣(ឃ)។

ដំណាក់កាលដំបូង។ ការខ្វះខាតបែបនេះ គឺកាន់តែបង្កើតបញ្ហាថែមទៀត ដោយពិចារណាដល់សម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ ដែលមិនទាន់បានដោះស្រាយនៅឡើយ។

ឃ. ជាចុងបញ្ចប់ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានតម្រូវឲ្យមានការជូនដំណឹងជាមុនទាក់ទងនឹងសិទ្ធិបញ្ជាក់ភស្តុតាងក្នុងពេលសវនាការថា: "*រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល* ជនជាប់ចោទ [...] អាច [...] ជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត"[11]។ មេធាវីការពារក្តីបានជំទាស់យ៉ាងរឹងមាំទៅនីតិវិធីដែលមានស្រាប់របស់ប្រទេសកម្ពុជា ដែលមិនស្របគ្នា ដោយបានយោងយ៉ាងជាក់លាក់ទៅនឹងមាត្រា ១២(១) នៃកិច្ចព្រមព្រៀង អវតក[12]។

ជាការពិតកត្តាទាំងនេះប៉ះពាល់ដល់វិធានការរបស់មេធាវីការពារក្តី ក្នុងការបង្ហាញឯកសារក្នុងសវនាការលើអង្គសេចក្តី ដូចនេះជាការមិនសមរម្យ និងក៏មិនចាំបាច់ទេ *នៅពេលនេះ* ដើម្បីផ្តល់ការបញ្ជាក់ដែលបានស្នើដោយអង្គជំនុំជម្រះនៅក្នុងសំណើបញ្ជាក់ឯកសារ។

៣. ដូចដែលបានបញ្ជាក់រួចមកហើយ មេធាវីការពារក្តី នឹងប្រឹងប្រែងជូនដំណឹងទៅអង្គជំនុំជម្រះ និងភាគីអំពីឯកសារថ្មីដែលខ្លួនមានបំណងយកទៅសំអាងក្នុងសវនាការនៅពេលវេលាសមស្រប និងឲ្យបានមុនកាលកំណត់នៃការស្នើសុំឯកសារនេះ[13]។ ជំហរនេះនឹងមិនប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ដែលមានចែងនៅក្នុងច្បាប់កម្ពុជា ក្នុងការលើកយកមកសំអាងនូវសម្ភារៈណាមួយដែលគាត់យល់ឃើញថា *មានប្រយោជន៍ដល់ការសំដែងឲ្យឃើញនូវការពិត* ឡើយដរាបណាឯកសារទាំងនេះត្រូវបានដាក់ជូននៅមុនការបិទដំណើការនីតិវិធីពិភាក្សាដេញដោល។ រួមទាំងភស្តុតាងដោះបន្ទុកជាសក្តានុពលដែរ

---

[11] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៣៤ (បញ្ជាក់បន្ថែម)។

[12] សូមមើលឯកសារ **E-51/3** "អញ្ញត្រកម្មរួម" ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ERN 00648279–00648310។

[13] សំគាល់មេធាវីការពារក្តី បានបញ្ជាក់រួចមកហើយថា ខ្លួនទំនងជា ដាក់ឯកសារទាំងអស់ដែលខ្លួនយោងលើក្នុងសំណើស៊ើបអង្កេតនានានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ព្រមទាំងឯកសារជាក់លាក់នៅក្នុង SMD ដែលទាក់ទងនឹងបញ្ហាបរិបទ ដែលបានបង្ហាញក្នុងសេចក្តីសង្ខេប។ សូមមើលសារណាបឋម, កថាខណ្ឌ ៥។ ដោយពិចារណាដល់វិធានការរបស់អង្គជំនុំជម្រះរហូតមកដល់ពេលនេះ វាហាក់ដូចជាឯកសារទាំងនោះនឹងត្រូវបានគិតថា មិនពាក់ព័ន្ធ។

ការដាក់ឯកសារថ្មីនេះ ក៏រួមបញ្ចូលឯកសារទាំងឡាយណាដែលអាចជំទាស់ទៅនឹងភាពអាចជឿជាក់បានរបស់សាក្សីប្រឆាំង។ ចំពោះឯកសារទាំងនេះ មេធាវីការពារក្តីគិតថា ជាការសំខាន់ក្នុងការតទល់ជាមួយសាក្សីដាក់បន្ទុកដោយមិនមានការជូនដំណឹងចំពោះបុគ្គលជាក់លាក់ ដែលនឹងត្រូវផ្តល់ចម្លើយ (និងមានការជូនដំណឹងតិចតួចដល់ភាគីផ្សេងទៀត)។ នៅគ្រប់ករណីទាំងអស់មេធាវីការពារក្តី នឹងចាត់វិធានការដើម្បី ធានាថា ឯកសារដែលប្រើក្នុងសវនាការ នឹងត្រូវបានបកប្រែជាភាសាផ្លូវការរបស់តុលាការ[14]។

## III. សេចក្តីសន្និដ្ឋាន

៤. តាមហេតុផលរៀបរាប់ខាងលើ និងអ្វីដែលបានលើកឡើងរួចមកហើយ មេធាវីការពារក្តី មិនយល់ព្រមនឹងសំណើបញ្ជាក់ឯកសារ *ក្នុងពេលនេះ* ទេ។

**សហមេធាវីការពារក្តីលោក នួន ជា**



**សុន អរុណ**



Michel PESTMAN & Victor KOPPE

[14] សំគាល់ ការធានាបែបនេះ នឹងបន្ធូរបន្ថយកង្វល់របស់អង្គជំនុំជម្រះអំពីការបកប្រែឯកសារ ដែលបានលើកឡើងក្នុងពេលសវនាការបឋម។ សូមមើល ប្រតិចារិតសវនាការបឋម ទំព័រ ២៥:១៦-១៩ (“ការបញ្ជាក់មុននេះនឹងអនុញ្ញាតឲ្យ អង្គភាពបកប្រែបញ្ជាក់អំពីស្ថានភាពបកប្រែឯកសារសំខាន់ៗ និង អង្គជំនុំជម្រះបង្ហាញអំពីភាពលំបាកដែលនឹងអាចមានតាមឆាប់ដែលអាចធ្វើទៅបាន”)។